00722564



**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**


**ឯកសារបកប្រែ**

**TRANSLATION/TRADUCTION**

ថ្ងៃ ខែ ឆ្នាំ (Date): 05-Aug-2011, 11:22

CMS/CFO: Uch Arun


**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ:/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបរបស់ លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឱ្យបើកសវនាការដោយផ្ទាល់មាត់ជាសាធារណៈ

---

**<u>ដាក់ដោយ÷</u>**

**សហមេធាវី÷**

អាង ឧត្តម

Michael G. KARNAVAS

**<u>អង្គជំនុំជម្រះសាលាដំបូង÷</u>**

ចៅក្រម **និល ណុន**

ចៅក្រម **ធូ មណី**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តរា**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") លោក អៀង សារី សូមដាក់ចម្លើយតបចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសន្និដ្ឋានរបស់ ក.ស.ព")[១]។ ក.ស.ព បកស្រាយមិនត្រឹមត្រូវទៅលើច្បាប់ជាធរមាន ហើយធ្វើសេចក្តីសន្និដ្ឋានដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយមិនផ្តល់ឱ្យ លោក អៀង សារី នូវសិទ្ធិក្នុងការតទល់សាក្សីនានា ដែលចម្លើយរបស់ពួកគាត់ត្រូវបានបង្ហាញ។ ការធ្វើបែបនេះវាផ្ទុយទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ សិទ្ធិរបស់លោក អៀង សារី ក្នុងការតទល់សាក្សី មិនគួរត្រូវបានដកហូត ឬរឹតត្បិត ដូចដែល ក.ស.ព បានស្នើឡើងថា ការធ្វើបែបនេះនឹងធ្វើឱ្យមានភាពងាយស្រួល ឬសមស្របតាមការប៉ាន់ស្មានរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូង គួរបដិសេធចោលសេចក្តីសន្និដ្ឋានរបស់ ក.ស.ព។ មេធាវីការពារក្តីសូមស្នើថាអង្គជំនុំជម្រះ បើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈមួយលើបញ្ហានេះ។

## I. សេចក្តីសង្ខេបលើសេចក្តីសន្និដ្ឋានរបស់ ក.ស.ព និងចម្លើយតបរបស់មេធាវីការពារក្តី

១. ការអះអាងសំខាន់ៗរបស់ ក.ស.ព មានដូចតទៅ[២]៖

ក. ជនជាប់ចោទមិនមានសិទ្ធិដាច់ខាតណាមួយទេ ក្នុងការសាកសួរដេញដោលសាក្សីនៅពេលសវនាការ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួល

[១] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E96។

[២] សេចក្តីសង្ខេបនៅក្នុងអត្ថបទនេះគឺផ្អែកទៅលើសេចក្តីសង្ខេបទឡ្ហីករណ៍របស់ ក.ស.ព។ ទឡ្ហីករណ៍ជាក់ស្តែងរបស់ ក.ស.ព មានរចនាសម្ព័ន្ធខុសពីនេះ ហើយមានលក្ខណៈពិបាកក្នុងការតាមយល់ ដោយហេតុថាទឡ្ហីករណ៍នោះភាគច្រើនមាននៅក្នុងផ្នែកដែលរៀបរាប់អំពីអង្គច្បាប់ នៅក្នុងសារណារបស់ ក.ស.ព។ ក.ស.ព ទំនងជាអះអាងថា វិធានផ្ទៃក្នុងមិនមានភាពច្បាស់លាស់ ហើយហេតុដូច្នេះ វិធានស្តីពីនីតិវិធីដែលត្រូវបានបង្កើតឡើងនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប និងនៅសាលាក្តីអន្តរជាតិពិសេសៗដទៃទៀត គួរត្រូវបានអនុវត្តតាម ជាជាងការអនុវត្តតាមវិធានស្តីពីនីតិវិធីដែលមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារការធ្វើបែបនេះនឹងការពារដល់ភាពងាយស្រួលនៃកិច្ចដំណើរការនីតិវិធី។

យកចម្លើយសាក្សី ដោយមិនមានធ្វើការកោះហៅសាក្សី ដើម្បីឱ្យមកផ្តល់សក្ខីកម្មនៅពេលសវនាការឡើយ[៣]។

ខ. អង្គជំនុំជម្រះសាលាដំបូង អាចនឹងអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន "ក្នុងការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីណាម្នាក់បាន និងតម្រូវឱ្យសាក្សីរូបនោះចូលមកបង្ហាញខ្លួន ដើម្បីធ្វើការសាក់សួរនៅពេលសវនាការ បើកំណត់ហេតុស្តាប់ចម្លើយនោះទាក់ទងទៅនឹង៖ (១) អំពើ និងអាកប្បកិរិយារបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់ណាមួយដែលនៅក្បែរជនជាប់ចោទ ឬ (២) បញ្ហាស្នូលនៅក្នុងរឿងក្តីនោះ"[៤]។ ហើយ

គ. ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះគួរតែត្រូវបានធ្វើតាមការណែនាំពី៖ "(១)ករណីយកិច្ចដែលសំខាន់ជាងអ្វីៗឯទៀតរបស់អង្គជំនុំជម្រះ ដើម្បីធានាឱ្យមានការជំនុំជម្រះមួយដែលត្រឹមត្រូវ (២) គោលការណ៍ផ្សេងៗទៀតរបស់ខ្លួនដែលគ្រប់គ្រងលើដំណើរការនីតិវិធី ដូចជា កាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ ជាដើម (៣) នីតិវិធីប្រព័ន្ធច្បាប់ស៊ីវិលជាធរមាននៅចំពោះមុខ អ.វ.ត.ក ដែលបានសង្កត់ធ្ងន់យ៉ាងសំខាន់ទៅលើការប្រើប្រាស់នូវកំណត់ត្រាជាលាយលក្ខណ៍អក្សរនានា ដែលចៅក្រមស៊ើបអង្កេតបានប្រមូល (៤) គោលការណ៍អន្តរជាតិនានាដែលបានអំពាវនាវឱ្យមានេះវិធីសាស្ត្រមួយដែលមានលក្ខណៈបត់បែន ក្នុងការទទួលយកនូវភស្តុតាង នៅក្នុងករណីនានាដែលមានឧក្រិដ្ឋដ៏រង្គាល និង (៥) វិសាលភាពនៃរឿងក្តី និងចរិតលក្ខណៈនៃការលើកឡើងចោទប្រកាន់លើជនជាប់ចោទ"[៥]។

២. មេធាវីការពារក្តីសូមឆ្លើយតបដោយមានទឡ្ហីករណ៍ក្បោះក្បាយខាងក្រោមដែលបញ្ជាក់ថា ៖

ក. លោក អៀង សារី មានសិទ្ធិដាច់ខាត ដើម្បីសាកសួរសាក្សី ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងរូបគាត់

ខ. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា លោក អៀង សារី មិនមានសិទ្ធិដាច់ខាត់

---

[៣] សារណារបស់ ក.ស.ព កថាខណ្ឌទី ២។

[៤] *ដូចលេខយោងជើងទំព័រខាងលើ*។

[៥] *ដូចលេខយោងជើងទំព័រខាងលើ*។

នេះទេនោះ អង្គជំនុំជម្រះត្រូវពិចារណាដោយប្រុងប្រយ័ត្នក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយ ដោយហេតុថា កំណត់ហេតុទាំងនេះជាច្រើន (បើទោះជាមិនមែនទាំងអស់ក្តី) ខ្វះភាពអាចឱ្យជឿជាក់បាន។

II. ***ការសង្កេតបឋម: ការលេចចេញនូវបមូលដ្ឋានខុសគ្នា***

៣. សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា គឺជាសារណាចំនួន ១៥ ទំព័រលើបញ្ហានីតិវិធី ដែលមានសំណើសុំ ដោយគ្មានមូលដ្ឋាននៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធាន")ឡើយ។ ដូចដែល ក.ស.ព ធ្លាប់បានទទួលស្គាល់ថា "អង្គជំនុំជម្រះសាលាដំបូង មិនមែនជាវេទិការត្រឹមត្រូវសម្រាប់ស្វែងរកឱ្យមានការកែប្រែវិធានផ្ទៃក្នុងទេ"[៦]។ ប្រសិនបើ ក.ស.ព ជឿជាក់ថា លោក អៀង សារី ឬជនជាប់ចោទដទៃទៀត មិនគួរមានសិទ្ធិសាកសួរសាក្សីទេនោះ ក.ស.ព គួរតែបានស្នើសុំឱ្យធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង។ ប៉ុន្តែ ក.ស.ព មិនបានធ្វើដូច្នេះនោះទេ ផ្ទុយទៅវិញ ក.ស.ព បែរជាដាក់ពាក្យសុំ "ជាច្រើនទំព័រ" ដែលគ្មាន "មូលដ្ឋានអង្គច្បាប់អ្វីសោះ"[៧]។ នៅពេលដែលមេធាវីការពារក្តីដាក់ញត្តិ "ជាច្រើនទំព័រ" ពាក់ព័ន្ធទៅនឹងបញ្ហានីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់ភាគីដទៃទៀតមិនឱ្យដាក់ចម្លើយតប ហើយបានណែនាំដល់អង្គភាពបកប្រែភាសាមិនឱ្យបកប្រែញត្តិទាំងនោះ[៨]។ ផ្ទុយទៅវិញ ចំពោះសេចក្តីសន្និដ្ឋានរបស់ ក.ស.ព អង្គជំនុំជម្រះសាលាដំបូងបានទទួលយកការដាក់ឯកសារនេះ ហើយថែមទាំងអនុញ្ញាតឱ្យ ក.ស.ព ដាក់ការ

[៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ០០២ ទៅតាមវិសោធនកម្មនីតិវិធី ដែលបានស្នើឡើង និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ឱ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E/9/3/1 កថាខណ្ឌទី ២(ក)។

[៧] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ០០១ ដែលបានវិនិច្ឆ័យរួចហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E69/1 ទំព័រទី ៣ ដែលនៅទំព័រនោះ អង្គជំនុំជម្រះបានលើកឡើងថា មេធាវីការពារក្តីបានដាក់ពាក្យសុំ "ដែលមានច្រើនទំព័រ" ដោយ "មិនមានមូលដ្ឋានផ្លូវច្បាប់"។

[៨] *ដូចលេខយោងជើងទំព័រខាងលើ*។ សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E71/1។

ឆ្លើយតបរបស់ខ្លួន មុនពេលមានសំណើសុំធ្វើដូច្នេះទៅទៀត[៩]។ ការអនុវត្តនីតិវិធីខុសគ្នាបែបនេះ នាំឱ្យលេចឡើងនូវបទដ្ឋានខុសគ្នា ដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ លោក អៀង សារី។

III. **ចម្លើយតប**

**ក. លោក អៀង សារី មានសិទ្ធិដាច់ខាត ដើម្បីសាកសួរសាក្សីនានា ដែលធ្វើសក្ខីកម្មប្រឆាំងនឹងរូបគាត់**

**១. វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្តល់ឱ្យ លោក អៀង សារី នូវសិទ្ធិដាច់ខាតដើម្បីសាកសួរសាក្សីនានាដែលធ្វើសក្ខីកម្មប្រឆាំងនឹងរូបគាត់**

៤. សិទ្ធិរបស់ជនជាប់ចោទណាមួយ ក្នុងការពិនិត្យ ឬសាកសួរសាក្សីនានា ដែលធ្វើសក្ខីកម្មប្រឆាំងលើរូបគាត់ គឺជាសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវបានធានាដោយកិច្ចព្រមព្រៀង[១០] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[១១] និង ICCPR[១២] ដែលប្រទេសកម្ពុជាត្រូវតែគោរព ដោយអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន[១៣]។ សិទ្ធិនេះត្រូវបានពណ៌នាថាជា

---

[៩] *សូមមើល* សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅកាន់ភាគីទាំងអស់ ស្តីអំពី ការកែប្រែឱសានុវាទដែលស្នើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការរកឃើញថ្មីៗចំនួនបីរបស់ព្រះរាជអាជ្ញា។ សេចក្តីជូនដំណឹងទុកជាមុនស្តីពីឱសានុវាទនៃការដាក់បញ្ជីភស្តុតាង/ឯកសារបន្ថែម (សម្រាប់ការជំនុំជម្រះក្តីដំណាក់កាលទីមួយ) ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើការពន្យារពេល ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E107។

[១០] កិច្ចព្រមព្រៀង មាត្រា ១៣(១)

[១១] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ៣៥ ថ្មី។

[១២] មាត្រា១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងនឹងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ ...(ង) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក..."។

[១៣] *សូមមើល* រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩ មាត្រា ៣១។

"មូលដ្ឋានសម្រាប់សញ្ញាណជឿនលឿននៃការជំនុំជម្រះក្តីដោយយុត្តិធម៌"[១៤] ហើយត្រូវបានទទួលស្គាល់ទាំងនៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល និងនៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ខំមិនឡ [១៥]។ នៅសហរដ្ឋអាមេរិក[១៦] និងនៅបណ្តាប្រទេសមួយចំនួនទៀត សិទ្ធិនេះគឺជាសិទ្ធិដែលមានធម្មនុញ្ញភាព[១៧]។ សិទ្ធិនេះ "អាចមានមូលដ្ឋានទៅលើសិទ្ធិស្វ័លរបស់ជនជាប់ចោទ ដើម្បីប្រឆាំងនឹងសាលក្រមដែលមិនមានភាពត្រឹមត្រូវទៅតាមអង្គហេតុ" និង "ជានីតិវិធីដ៏សំខាន់មួយដើម្បីវាយតម្លៃលើភស្តុតាង និងដើម្បីជួយដល់តុលាការសម្រេចថាតើតុលាការអាចពឹងផ្អែកលើភស្តុតាងនេះបានច្រើនកម្រិតណា"[១៨]។ "ការសាកសួរសាក្សីរបស់ភាគីបដិបក្ខ អាចឱ្យជនជាប់ចោទចូលរួមបានយ៉ាងពេញលេញនៅក្នុងការបង្ហាញភស្តុតាងទៅដល់អ្នកស្វែករកការពិត។ ស្វ័យភាព និងសេចក្តីថ្លៃថ្នូររបស់ជនជាប់ចោទ ត្រូវបានទទួលស្គាល់តាមរយៈការអនុញ្ញាតឱ្យគេបានស្តាប់ឮសម្លេងរបស់គាត់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយមិនគិតពីផលប៉ះពាល់នៃការសាក

---

[១៤] *R. v. Hughes*, 2 N.Z.L.R. 129, 148, *ដកស្រង់ក្នុង* Ian Dennis, *សិទ្ធិធ្វើការតទល់មុខគ្នាជាមួយសាក្សី៖ អត្ថន័យ, ជំនឿមិនពិត និងសិទ្ធិមនុស្ស The Right to Confront Witnesses: Meanings, Myths and Human Rights*, CRIM. L.R. 255, 255 (2010)។ សិទ្ធិនេះ "ត្រូវបានទទួលស្គាល់យ៉ាងទូលាយថាជាធាតុផ្សំសារវន្តនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ដូចគ្នាការសន្មតជាមុនថាគ្មានទោសដែរ។" *ដូចជើងទំព័រខាងលើ*។

[១៥] *សូមមើល* មាត្រា ៦(៣) (ឃ)នៃកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR") ដែលចែងបទប្បញ្ញត្តិដូចគ្នាទៅនឹងមាត្រា១៤ (៣) (ឃ)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ECHR ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋនៅក្នុងទ្វីបអឺរ៉ុបស្ទើរតែទាំងអស់ ដូច្នេះហើយត្រូវបានអនុវត្តនៅគ្រប់វិសាលភាពនៃប្រព័ន្ធច្បាប់។

[១៦] *សូមមើល* រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក វិសោធនកម្មលើកទី៦។ *សូមមើលផងដែរ Crawford v. Washington*, 541 U.S. 36 (2004) ត្រង់ចំណុចដែលតុលាការកំពូលសហរដ្ឋអាមេរិក បានច្រានចោលដាច់ខាតនូវការលើកឡើងថាវិសោធនកម្មលើកទី៦ គ្រាន់តែផ្តល់សិទ្ធិដល់ជនជាប់ចោទធ្វើការតទល់មុខគ្នានឹងសាក្សីដែលមានវត្តមានដោយផ្ទាល់នៅពេលជំនុំជម្រះក្តីប៉ុណ្ណោះ។

[១៧] STEFANO MAFFEI, សិទ្ធិរបស់ប្រជាជនអឺរ៉ុបក្នុងការតទល់មុខគ្នាក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ៖ សាក្សីដែលអវត្តមាន, អនាមិក និងងាយរងគ្រោះ *9 THE EUROPEAN RIGHT TO CONFRONTATION IN CRIMINAL PROCEEDINGS: ABSENT, ANONYMOUS AND VULNERABLE WITNESSES 9* (ការបោះពុម្ពផ្សាយច្បាប់ Europa ឆ្នាំ ២០០៦), ដកស្រង់អំពីរដ្ឋធម្មនុញ្ញប្រទេសអាល់បានី និងប្រទេសអ៊ីតាលី

[១៨] Ian Dennis, *សិទ្ធិធ្វើការតទល់មុខគ្នាជាមួយនឹងសាក្សី៖ អត្ថន័យ, ជំនឿមិនពិត និងសិទ្ធិមនុស្ស The Right to Confront Witnesses: Meanings, Myths and Human Rights*, CRIM. L.R. 255, 259 (2010)។

សួរនេះចំពោះការជឿជាក់បាននៃភស្តុតាង និងលទ្ធផលដែលអាចកើតមាននៃរឿងក្តីឡើយ"[១៩]។

៥. វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ជាភាសាអង់គ្លេស ចែងថា "ជនជាប់ចោទមានសិទ្ធិស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទ មិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ"។ ក.ស.ព អះអាងថាមានភាពមិនស៊ីសង្វាក់គ្នានៅក្នុងការបកប្រែជាភាសាអង់គ្លេស បារាំង និង ខ្មែរ នៃវិធាន ៨៤(១) ហើយអត្ថន័យនៃឃ្លាថា "សាក្សីដាក់បន្ទុក" មាន "លក្ខណៈស្រពិចស្រពិល"[២០]។

៦. ភាពមិនស៊ីសង្វាក់គ្នានៅក្នុងការបកប្រែភាសានៃវិធាន ៨៤(១) មិនសំខាន់នោះទេ។ អត្ថបទនៃវិធាន ៨៤(១) ក្នុងភាសានីមួយៗ បញ្ជាក់ច្បាស់ថា លោក អៀង សារី មានសិទ្ធិកោះហៅសាក្សីដែលគាត់មិនមានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ។ អត្ថន័យនៃឃ្លា "សាក្សីដាក់បន្ទុក" មិនមានភាពស្រពិចស្រពិលឡើយ។ វាគឺជាឃ្លាដែលគេប្រើជាទូទៅនៅក្នុងលិខិតុបករណ៍ជាច្រើន *ក្នុងចំណោមនោះ (inter alia)* មានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[២១] អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប[២២] និងនៅក្នុងធម្មនុញ្ញរបស់សហរដ្ឋអាមេរិក[២៣]។ អត្ថន័យនៃឃ្លានេះត្រូវបានពិចារណាដោយបណ្តាតុលាការ និងវិទូផ្នែកច្បាប់[២៤]។ ជាឧទាហរណ៍ តុលាការជាន់ខ្ពស់របស់សហរដ្ឋអាមេរិក បានសម្រេចថា សិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់ទៅនឹង "សាក្សីដាក់បន្ទុក" មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក៖

---

[១៩] *ដូចដើងទំព័រខាងលើ,* នៅកថាខណ្ឌ 266។

[២០] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 4 ។

[២១] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤ (៣) (ង)។

[២២] កតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) មាត្រា ៦ (៣) (ឃ)។

[២៣] រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក វិសោធនកម្មលើកទី៦

[២៤] យោងតាមបណ្ឌិត Stefano Maffei " ប្រសិនបើតុលាការទទួលស្គាល់ថាជាការពិតនោះ សាក្សី[មួយរូប] ដាក់បន្ទុកលើជនជាប់ចោទ នៅពេលដែលសក្ខីកម្មរបស់ខ្លួន អាចផ្តល់ផលប៉ះពាល់អវិជ្ជមានសម្រាប់ការការពារក្តីក្នុងរឿងក្តីនោះ។" STEFANO MAFFEI, សិទ្ធិរបស់ប្រជាជនអឺរ៉ុបក្នុងការតទល់មុខគ្នាក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ៖ សាក្សីដែលអវត្តមាន, អនាមិក និងងាយរងគ្រោះ 19 *THE EUROPEAN RIGHT TO CONFRONTATION IN CRIMINAL PROCEEDINGS: ABSENT, ANONYMOUS AND VULNERABLE WITNESSES 19* (ការបោះពុម្ពផ្សាយច្បាប់ Europa ឆ្នាំ ២០០៦)។

អាចអនុវត្តបានចំពោះ "សាក្សី" ដាក់បន្ទុកប្រឆាំងនឹងជនជាប់ចោទ។ មានន័យថា អ្នកទាំងឡាយណា ដែល "ផ្តល់សក្ខីកម្ម"។ "សក្ខីកម្ម" ជាទូទៅ គឺជា "ការប្រកាស ឬការបញ្ជាក់ដ៏ច្បាស់លាស់ ដែលត្រូវបានធ្វើឡើង ក្នុងគោលបំណងបង្កើតឱ្យមាននូវ ឬ បញ្ជាក់អំពីការពិតណាមួយ"... ទម្រង់នានានៃកំណត់ហេតុស្នូលនៃ "សក្ខីកម្ម" នេះមានដូចជា៖ "សក្ខីកម្មរបស់ភាគីតែម្ខាងនៅក្នុងតុលាការ ឬ សក្ខីកម្មដែលមានតម្លៃស្មើ មានដូចជា សម្ភារៈ ឧទាហរណ៍ កំណត់ហេតុជាលាយលក្ខណ៍អក្សរដែលធ្វើឡើងក្រោមសម្បថ ការសាកសួរក្នុងអំឡុងពេលឃុំខ្លួនបណ្តោះអាសន្ន សក្ខីកម្មដែលមានមុនរួចជាស្រេចដែលជនជាប់ចោទមិនអាចតទល់បាន ឬកំណត់ហេតុមុនអង្គសេចក្តីស្រដៀងគ្នានេះ ដែលអ្នកផ្តល់ឱ្យអាចរំពឹងទុកជាមុនដោយសមហេតុផលថានឹងអាចយកមកប្រើប្រាស់នៅក្នុងការចោទប្រកាន់បាន"... "កំណត់ហេតុដែលត្រូវបានធ្វើឡើងក្រោមកាលៈទេសៈដែលអាចឱ្យអ្នកសង្កេតសត្យានុម័តមួយរូបជឿដោយសមហេតុផលថា កំណត់ហេតុនេះនឹងអាចមានសម្រាប់ប្រើប្រាស់នៅក្នុងដំណាក់កាលបន្ទាប់មកទៀតនៃការជំនុំជម្រះក្តី"... ទម្រង់ទាំងនេះសុទ្ធតែមានលក្ខណៈស្នូលរួម ហើយកំណត់នូវព្រំដែននៃខបញ្ញត្តិនេះ ដោយមានកម្រិតអរូបិយនានានៅជុំវិញខបញ្ញត្តិនេះ[២៥]។

៧. ដោយពិចារណាទៅលើ វិធាន ៨៤(១) នៃវិធានផ្ទៃក្នុងជាមួយគ្នានឹងវិធានដទៃទៀត បង្ហាញឱ្យឃើញថា អ្នកធ្វើពង្រាងវិធានទាំងនេះមានបំណងគោរពនូវសិទ្ធិរបស់ជនជាប់ចោទ ក្នុងការសាកសួរសាក្សី។ វិធាន ២៦(១) នៃវិធានផ្ទៃក្នុងចែងថា៖

សក្ខីកម្មរបស់សាក្សី ឬ អ្នកជំនាញ... នៅក្នុងអំឡុងពេលនៃការជំនុំជម្រះត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យសាក្សីធ្វើសក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍ ក្នុងករណីដែលបច្ចេកវិទ្យាបែបនេះអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ និងភាគីសាកសួរសាក្សីបាន នៅពេលដែលសាក្សីត្រូវធ្វើសក្ខីកម្ម។ <u>បច្ចេកវិទ្យានេះមិនត្រូវអនុញ្ញាតឱ្យប្រើទេ ប្រសិនបើធ្វើឱ្យមានអន្តរាយធ្ងន់ធ្ងរ ឬ មិនស្របទៅនឹងសិទ្ធិការពារខ្លួន</u>[២៦]។

៨. វិធាន ២៨(៧)(ក) នៃវិធានផ្ទៃក្នុង លើកឡើងអំពីលទ្ធភាពក្នុងការផ្តល់អានុភាពនៃការធានាឱ្យទៅសាក្សី ដើម្បីធានាថាសក្ខីកម្មរបស់ពួកគាត់នឹងត្រូវរក្សាទុកជាសម្ងាត់ ហើយនឹងមិនត្រូវប្រើប្រាស់ដើម្បីដាក់បន្ទុកលើខ្លួនឯងឡើយ។ វិធាននេះក៏បានលើកឡើងពីលទ្ធភាពក្នុងការអនុញ្ញាតឱ្យសាក្សីធ្វើសក្ខីកម្មដោយសម្ងាត់។ ប៉ុន្តែ វិធាននេះមិនបានចែងពីលទ្ធភាពក្នុងការអនុញ្ញាតឱ្យដាក់កំណត់

[២៥] *Crawford v. Washington*, 541 U.S. 36, 51-52 (U.S. 2004) (ឯកសារយោងផ្ទៃក្នុងត្រូវបានលុបចេញ)។

[២៦] គូសបញ្ជាក់បន្ថែម។

ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះ *ជំនួសឱ្យ*សក្ខីកម្មដោយផ្ទាល់មាត់ឡើយ។

៩. វិធាន ២៩(៣) និង ២៩(៤) ចែងថា៖

៣. ...សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់វិធានការសមស្រប ដើម្បីការពារអ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលមកបង្ហាញខ្លួនប្រសិនបើការបង្ហាញខ្លួននោះ អាចធ្វើឱ្យអាយុជីវិត សុខមាលភាព ឬ ក្រុមគ្រួសារ ឬ ញាតិជិតស្និទ្ធរបស់ពួកគេត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ...

៤. ក្នុងបរិបទនេះ សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះ អាចចេញសេចក្តីបង្គាប់ដោយមានសំអាងហេតុ ចាត់វិធានការដើម្បីការពារអត្តសញ្ញាណជនទាំងនោះ ដូចជា...

គ. អនុញ្ញាតឱ្យធ្វើកំណត់ហេតុសួរយកចម្លើយរបស់ជននោះ ដោយមិនចាំបាច់សរសេរអត្តសញ្ញាណរបស់ជននោះនៅក្នុងសំណុំរឿង។

ឃ. <u>នៅពេលណាជនត្រូវចោទ ឬ ជនសង្ស័យស្នើឱ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឱ្យមានការចូលរួមពីចម្ងាយ ឬ បំផ្លែងសម្លេងដើម ឬ បិទបាំងភិនភាគរបស់ជននោះ</u>...[២៧]

វិធានទាំងនេះបង្ហាញឱ្យឃើញថា សក្ខីកម្មដោយផ្ទាល់មាត់ ត្រូវបានប្រមើលទុកមុនសម្រាប់គ្រប់សាក្សីទាំងអស់។ សិទ្ធិរបស់ជនជាប់ចោទ ដើម្បីសាកសួរសាក្សីត្រូវតែគោរព បើទោះជាត្រូវចាត់វិធានការការពារជាក់លាក់ណាក៏ដោយ ដែលមិនត្រូវប៉ះពាល់ដល់ ឬ មិនស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទឡើយ។

១០. ក.ស.ព ទទួលព័ត៌មានមិនត្រឹមត្រូវ នៅពេលដែលខ្លួនអះអាងថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានផ្តល់សេចក្តីណែនាំលើបញ្ហានេះ[២៨]។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានលក្ខណៈស្របទៅនឹងការអានដ៏សាមញ្ញទៅលើវិធាន ៨៤(១) ជាភាសាអង់គ្លេស។ មាត្រា ២៩៧ ចែងថា "សាក្សី

---

[២៧] គូសបញ្ជាក់បន្ថែម។

[២៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 4។

ខាងដាក់បន្ទុក ដែលមិនទាន់បានសួរសម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែ[២៩] កោះហៅឱ្យចូលរួមក្នុងសវនាការ"[៣០]។ នៅក្នុងភាសាខ្មែរ ពាក្យដែលត្រូវបកប្រែថា "ដាក់បន្ទុក" នៅក្នុងមាត្រាមួយនេះ គឺជាពាក្យដូចគ្នាប្រើនៅក្នុងវិធាន ៨៤(១) ជាភាសាខ្មែរ ដែលត្រូវបានបកប្រែទៅជាភាសាអង់គ្លេសថា "សាក្សីប្រឆាំងនឹងជនជាប់ចោទ"។

១១. ក.ស.ព អះអាងថា ប្រសិនបើវិធាន ៨៤(១) នៃវិធានផ្ទៃក្នុងនេះត្រូវបានបកស្រាយថាជាសិទ្ធិដាច់ខាតនោះ វានឹងមិនស្របគ្នាទៅនឹងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង[៣១]។ ក.ស.ព មិនបានបង្ហាញឱ្យឃើញនូវភាពមិនស្របគ្នានេះទេ។ ក.ស.ព កត់សម្គាល់ថា វិធាន ២១(១)(ក) តម្រូវឱ្យតុលាការរក្សាតុល្យភាពសិទ្ធិរបស់ភាគីនីមួយៗ[៣២] ដោយចង់មានន័យថា ការគោរពវិធាន ៨៤(១) នឹងធ្វើឱ្យប៉ះពាល់ដល់តុល្យភាពនេះ។ ផ្ទុយទៅវិញ វិធាន ២១(១)(ក) ស្របទៅនឹង និងគាំទ្រទៅដល់វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង។ វិធាន ៨៤(១) មិនកំហិតសិទ្ធិរបស់ ក.ស.ព ឬ ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ មានមូលហេតុសំខាន់ៗជាច្រើន បញ្ជាក់ថាហេតុអ្វីបានជាវិធាន ៨៤(១) សំដៅជាពិសេសទៅលើជនជាប់ចោទថាមានសិទ្ធិកោះហៅសាក្សី៖

> ជនជាប់ចោទគឺជាប្រធានបទនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលជាបុគ្គលសំខាន់។ គាត់គឺជាបុគ្គលដែលត្រូវបានចោទប្រកាន់ ហើយដូច្នេះ គឺជាបុគ្គលដែលប្រឈមនឹងការសម្រេចឱ្យមានទោស និងត្រូវផ្តន្ទាទោស។ ភស្តុតាងនៅក្នុងសំណុំរឿងត្រូវបានផ្តោតទៅលើពិរុទ្ធភាពនៃបទល្មើសរបស់គាត់ដែលត្រូវបានចោទថាមាន។ ច្បាស់ណាស់ សង្គមទូទៅ និងជនរងគ្រោះនៃបទល្មើសជាពិសេស មានការចាប់អារម្មណ៍ជាពិសេសទៅលើតម្លៃនៃភស្តុតាង និងភាពត្រឹមត្រូវជាក់ស្តែងនៃសាលក្រម ដែលត្រូវបានធ្វើឡើយផ្អែកលើភស្តុតាងនេះ។ ប៉ុន្តែ ជនជាប់ចោទ មានការចាប់អារម្មណ៍ជាពិសេសដោយឡែក ដោយហេតុថាប្រសិនបើសាលក្រមប្រកាសពីពិរុទ្ធភាព មិនត្រឹមត្រូវទេនោះ គាត់គឺជាបុគ្គលមួយរូបដែលនឹងទទួលរងនូវការស្តីបន្ទោស និងផ្តន្ទាទោសដោយអយុត្តិធម៌[៣៣]។

---

[២៩] ពាក្យប្រើក្នុងឯកសារជាភាសាខ្មែរ ក៏បកប្រែថា "must ត្រូវតែ" ក្នុងអង់គ្លេស។

[៣០] គូសបញ្ជាក់បន្ថែម។

[៣១] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 4។

[៣២] *ដូចជើងទំព័រខាងលើ។*

[៣៣] Ian Dennis, *សិទ្ធិធ្វើការតទល់គ្នានឹងសាក្សី៖ អត្ថន័យ, ជំនឿមិនពិត និងសិទ្ធិមនុស្ស The Right to Confront Witnesses: Meanings, Myths and Human Rights*, CRIM. L.R. 255, 259 (2010)។

**២. មិនមានចន្លោះប្រហោងនៅក្នុងវិធានទាំងនេះនោះទេ ហេតុដូច្នេះ មិនមានមូលហេតុណាមួយ ដែលត្រូវពិចារណាទៅលើវិធានស្តីពីនីតិវិធីនៅក្នុងកម្រិតអន្តរជាតិនោះដែរ**

១២. ក.ស.ព អះអាងថា មានចន្លោះប្រហោងនៅក្នុងវិធានទាំងនេះ ដោយសារតែវិធានទាំងនេះមិនមានបទប្បញ្ញត្តិជាក់លាក់នានា ស្តីអំពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬ ប្រតិចារិតមកពីការជំនុំជម្រះក្តីដទៃទៀត ដូចមានចែងនៅក្នុងវិធាននានារបស់តុលាការពិសេសផ្សេងៗទៀតនោះទេ[៣៤]។ ក.ស.ព កត់សម្គាល់ថា វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក" ប៉ុន្តែ ក.ស.ព ក៏អះអាងថាមិនមានសេចក្តីណែនាំណាមួយស្តីអំពីទំនាក់ទំនងរវាងវិធាន ៨៧(១) និង វិធាន ៨៤(១) ដែរ[៣៥]។ ដោយសារតែការគិតថាមានភាពមិនច្បាស់លាស់ និងការគិតថាមានចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុងនេះហើយ ដែល ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងគួរតែស្វែងរកការណែនាំអំពីវិធាននីតិវិធីដែលត្រូវបានបង្កើតនៅក្នុងកម្រិតអន្តរជាតិ[៣៦]។ ហេតុដូច្នេះ ក.ស.ព ចង្អុលទៅកាន់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ហៅកាត់ថា "ICTY") តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (ហៅកាត់ថា "SCSL") និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ហៅកាត់ថា "ICC")។

១៣. បើយើងមិនគិតនូវអ្វីអាចជា ឬ មិនអាចជាការអនុវត្តលើកិច្ចដំណើរការនីតិវិធី ឬ លើអង្គសេចក្តីនៅតាមបណ្តាតុលាការអន្តរជាតិនានាក៏ដោយ ដូចបានបង្ហាញឱ្យឃើញពីខាងលើរួចហើយ វិធាន

---

[៣៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 5។

[៣៥] *ដូចជើងទំព័រខាងលើ*។

[៣៦] យោងតាមមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង៖ " នៅពេលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងនឹងភាពស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

ផ្ទៃក្នុងមានលក្ខណៈច្បាស់លាស់។ មិនមានចន្លោះប្រហោងនោះទេ។ ហេតុដូច្នេះ មិនមានហេតុផលសមស្របណាមួយដើម្បីពិចារណាទៅលើវិធានស្តីពីនីតិវិធី ដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិទេ។

១៤. វិធានផ្ទៃក្នុង "បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធទៅនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក"[៣៧]។ វិធានផ្ទៃក្នុងត្រូវបានបង្កើតឡើងជាពិសេស ដោយមានការពិចារណាទៅលើនីតិវិធីអន្តរជាតិ ដើម្បី "ធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក ហើយ... ដើម្បីអនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្ត ឬ ក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជា ទៅនឹងនិយាមអន្តរជាតិ"[៣៨]។ ហេតុដូច្នេះ មិនមានហេតុផលណាមួយ ដែលត្រូវពិចារណាឃើញថា វិធានផ្ទៃក្នុងត្រូវបានអនុម័ត ដោយគ្មានការពិចារណាទៅលើយុត្តិសាស្ត្រនៅតាមបណ្តាតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ICTY, SCSL ឬនៅ ICC នោះឡើយ។ ប្រសិនបើវិធានផ្ទៃក្នុងប្រាសចាកពីនីតិវិធីនៅតាមបណ្តាតុលាការទាំងនេះមែននោះ ក៏វាជាការប្រាស់ចាកដោយចេតនា ដោយសារតែកាលៈទេសៈពិសេសរបស់ អ.វ.ត.ក នោះដែរ។

១៥. ក.ស.ព អះអាងដោយមិនត្រឹមត្រូវថា "វិធានមិនបានចែងថាតើអង្គជំនុំជម្រះត្រូវធ្វើយ៉ាងដូចម្តេចដើម្បីដោះស្រាយអំពីទំនាក់ទំនងរវាងអនុវិធាន ៨៧.១ និង ៨៤.១ នោះឡើយ"[៣៩]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់ពន្យល់រួចហើយថា វិសាលភាពនៃវិធាន ៨៧(១) ត្រូវបានកំណត់ដោយវិធាន ៨៧(២) និង ៨៧(៣)៖

> ខណៈដែលសម្ភារៈដែលមាននៅក្នុងសំណុំរឿងអាចត្រូវបានលើកយកមកដេញដោលនៅចំពោះមុខអង្គជំនុំ

---

[៣៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ D55/I/8, កថាខណ្ឌ 14។

[៣៨] វិធានផ្ទៃក្នុង, បុព្វកថា។

[៣៩] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 5។

> ជម្រះសាលាដំបូង... អង្គជំនុំជម្រះអាចបដិសេធមិនយកមកធ្វើជាភស្តុតាងបានដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានគូសបញ្ជាក់នៅក្នុងវិធាន ៨៧(៣) ពោលគឺមិនជាប់ពាក់ព័ន្ធ មិនអាចបញ្ជាក់ពីអង្គហេតុដែលត្រូវបានចោទប្រកាន់ មិនអាចរកបានភស្តុតាងក្នុងរយៈពេលសមស្របណាមួយ ឬដោយសារតែល្មើសទៅនឹងបទដ្ឋានច្បាប់ជាមូលដ្ឋានពាក់ព័ន្ធនឹងវិធាននៃភស្តុតាង[៤០]។

អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើវិធាន ៨៧(៣) ដើម្បីដកចេញនូវចម្លើយរបស់សាក្សីដែលបានទទួលមរណភាព ដោយសម្រេចថាចម្លើយសាក្សីទាំងនោះ មិនសក្តិសមនឹងបង្ហាញពីការពិតដូចដែលត្រូវបានអះអាងនោះទេ ដោយសារតែប្រភព ខ្លឹមសារ ចរិតលក្ខណៈដែលត្រូវជំទាស់របស់ចម្លើយសាក្សីទាំងនេះ និងដោយសារជនជាប់ចោទមិនអាចតទល់លើភាពត្រឹមត្រូវរបស់ចម្លើយទាំងនេះបាន[៤១]។

១៦. យុត្តិសាស្ត្រនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលមិនគ្រប់គ្រងលើ អ.វ.ត.ក ទេនោះ បង្ហាញឱ្យឃើញថា តុលាការសិទ្ធិមនុស្សអឺរ៉ុបមិនពិចារណាអំពីសិទ្ធិក្នុងការសាកសួរសាក្សីថាជាសិទ្ធិដាច់ខាតទេ។ ប៉ុន្តែ នៅក្នុងករណីភាគច្រើនដែល ក.ស.ព បានយោងទៅលើ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពាន ហើយនៅក្នុងគ្រប់ករណីទាំងអស់ លើកលែងតែករណីចំនួនពីរតែប៉ុណ្ណោះ[៤២] ដែលសាក្សីមិនអាចរកបាន បដិសេធមិនធ្វើសក្ខីកម្ម ឬធ្វើសក្ខីកម្មក្នុងនាមជាជនអនាមិក។ មិនមានករណីណាមួយក្នុងចំណោមករណីដែល

---

[៤០] *សំណុំរឿង កាំង ហ្គេកអ៊ាវ* 001/18-07-2007-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩, E43/4, កថាខណ្ឌ 6។

[៤១] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ 16។

[៤២] ក្នុងរឿងក្តី *A.S. ទតល់នឹងប្រទេសហ្វាំងឡង់*, កិច្ចស្តាប់ចម្លើយដែលបានថតវីដេអូជាមួយជនរងគ្រោះដោយសារការរំលោភផ្លូវភេទ អាយុ៤ឆ្នាំ ត្រូវបានទទួលយក ហើយខាងជនជាប់ចោទ មិនត្រូវបានផ្តល់ឱកាសឲ្យសាកសួរកុមារនោះឡើយ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) យល់ឃើញថានោះជាការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ។ រឿងក្តី *A.S. ទតល់នឹងប្រទេសហ្វាំងឡង់*, Eur. Ct. H.R., ឯកសារដាក់ពាក្យលេខ 40156/07 (2010)។ ក្នុងរឿងក្តី *Luca ទតល់នឹងប្រទេសអ៊ីតាលី*, ជនម្នាក់ដែលត្រូវបានរកឃើញថាជាម្ចាស់សារធាតុកាកូអ៊ីន បានផ្តល់សក្ខីកម្មដល់រដ្ឋអាជ្ញាថាជនជាប់ចោទជាអ្នកលក់សារធាតុកាកូអ៊ីននោះឲ្យគាត់។ នៅពេលនោះ ជននោះ បានអនុវត្តសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ECtHR យល់ឃើញថាសិទ្ធិរបស់ជនជាប់ចោទ ត្រូវបានរំលោភបំពានពីព្រោះគាត់ត្រូវបានផ្តន្ទាទោស ផ្អែកលើសក្ខីកម្មនេះ, រឿងក្តី *Luca ទតល់នឹង* Italy, 2001-II Eur. Ct. H.R. 167 (2001)។

ក.ស.ព បានយោងទៅលើ បង្ហាញថាសិទ្ធិក្នុងការសាកសួរសាក្សី ត្រូវបានកំហិតដើម្បីគ្រាន់តែធ្វើឱ្យមានភាពងាយស្រួលប៉ុណ្ណោះឡើយ។ បញ្ហាសុវត្ថិភាពរបស់សាក្សី មិនទំនងថាកើតមាននៅក្នុងករណីនេះទេ ប៉ុន្តែ ប្រសិនបើមានពិតមែននោះ អ.វ.ត.ក ក៏មានវិធានគ្រប់គ្រាន់រួចទៅហើយ ដើម្បីដោះស្រាយស្ថានភាពបែបនេះ[៤៣]។ បន្ថែមលើនេះ យោងតាមយុត្តិសាស្ត្រនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប "យន្តការណាមួយដែលកំហិតសិទ្ធិរបស់ជនជាប់ចោទ គួរតែត្រូវយកមកអនុវត្តនៅពេលមានភាពចាំបាច់ខ្លាំង។ ប្រសិនបើមានយន្តការដែលកំហិតសិទ្ធិស្រាលជាងនេះ យន្តការនោះគួរត្រូវយកមកអនុវត្ត"[៤៤]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ទំនងជាអនុញ្ញាតឱ្យ ក.ស.ព ដាក់ចម្លើយសាក្សីនៅចំពោះមុខខ្លួន ដោយមិនកោះហៅសាក្សីទាំងនោះដើម្បីសាកសួរទេ ក.ស.ព ជាបឋម ត្រូវបង្ហាញឱ្យឃើញថា វាពិតជាចាំបាច់បំផុតសម្រាប់ធ្វើដូច្នេះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានយល់ឃើញរួចមកហើយថា៖ "ច្បាប់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបបង្ហាញថា សិទ្ធិក្នុងការពិនិត្យលើសាក្សី ដែលជាផ្នែកនៃសិទ្ធិក្នុងការទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ ជាធម្មតាបានសន្មតជាមុនថា ភស្តុតាងនឹងត្រូវនាំយកមកបង្ហាញនៅក្នុងសវនាការសាធារណៈ ដោយមានវត្តមានរបស់ជនជាប់ចោទ ដែលអាចមើលឃើញការជជែកតទល់គ្នា។ នៅពេលមានការលើកលែងចំពោះគោលការណ៍ទូទៅនេះ តាមវិធានទូទៅ ជនជាប់ចោទត្រូវបានផ្តល់នូវឱកាសគ្រប់គ្រាន់ និងសមស្រប ដើម្បីធ្វើការជំទាស់ និងអាចសួរសំណួរទៅសាក្សីដែលប្រឆាំងនឹងគាត់ផងដែរ..."[៤៥]។

១៧. ក.ស.ព ផ្អែកលើវិធានស្តីពីនីតិវិធីរបស់តុលាការ ICTY និង SCSL និងយុត្តិសាស្ត្រពាក់ព័ន្ធនានាយ៉ាងច្រើន[៤៦] ប៉ុន្តែ វិធានស្តីពីនីតិវិធីរបស់តុលាការទាំងពីរនេះ ចែងយ៉ាងជាក់លាក់ថា កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ អាចត្រូវបានទទួលយកនៅក្នុងកាលៈទេសៈជាក់លាក់មួយ

---

[៤៣] សូមមើលវិធាន 26, 29។

[៤៤] *រឿងក្តី Van Mechelen និងអ្នកដទៃទៀត ទល់នឹង Netherlands*, 1997-III Eur. Ct. H.R. (1997), កថាខណ្ឌ58។

[៤៥] *សំណុំរឿង កាំង ហ្គេកអ៊ាវ* 001/18-07-2007-អ.វ.ត.ក/អ.ជ.ស.ជ, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ E43/4, កថាខណ្ឌ14 (គូសបញ្ជាក់បន្ថែម)។

[៤៦] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព, កថាខណ្ឌ 12-27។

ចំនួន ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់[៤៧]។ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនមានបទប្បញ្ញត្តិដូចគ្នានេះទេ។ អ្នកធ្វើពង្រាងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ប្រាកដជាបានដឹងរួចហើយអំពីវិធានស្តីពីនីតិវិធីរបស់តុលាការ ICTY និង SCSL ហើយអាចអនុម័តវិធានណាមួយ ដែលស្រដៀង ឬ ដូចគ្នាទាំងស្រុងទៅនឹងវិធានរបស់តុលាការទាំងពីរនេះ ប្រសិនបើអ្នកធ្វើពង្រាងទាំងនោះយល់ថាចាំបាច់។ ការណ៍ដែលពួកគាត់មិនធ្វើដូច្នេះ គឺជាការបង្ហាញឱ្យឃើញថា នីតិវិធីនៅ អ.វ.ត.ក ខុសពីនីតិវិធីនៅតុលាការ ICTY និង SCSL[៤៨]។ ក.ស.ព មិនពិចារណាទៅលើភាពខុសគ្នាដ៏ច្បាស់ទាំងនេះរវាងប្រព័ន្ធនីតិវិធីរបស់ អ.វ.ត.ក និងតុលាការ ICTY និង SCSL ឡើយ។

១៨. តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គ្រាន់តែអនុញ្ញាតទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយមិនមានវត្តមានរបស់សាក្សីនៅក្នុងសវនាការ ប្រសិនបើក្រុមរដ្ឋអាជ្ញា និងក្រុមការពារក្តី មានឱកាសសាកសួរសាក្សីនោះរួចមកហើយ នៅពេលកត់ត្រាចម្លើយសាក្សីនោះ[៤៩]។ ក.ស.ព អះអាងថា វិធានរបស់ ICC "មិនសូវពាក់ព័ន្ធ" ពីព្រោះវិធានទាំងនោះមានចែងពីការរឹតត្បិតយ៉ាងច្បាស់លាស់ចំពោះការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ ខណៈដែលវិធានរបស់ អ.វ.ត.ក មិនមានចែងពីការរឹតត្បិតបែបនេះទេ[៥០]។ គេអាចអះអាងយ៉ាងងាយស្រួលដូចគ្នានេះដែរថា វិធានរបស់តុលាការ ICTY និង SCSL "ពាក់ព័ន្ធតិចជាង" វិធានរបស់ ICC ទៅទៀត ពីព្រោះថាវិធានទាំងនោះមានចែងយ៉ាងច្បាស់លាស់អំពីការអនុញ្ញាតឱ្យពឹងផ្អែកទៅលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដោយមិនមានវត្តមានរបស់សាក្សីទាំងនោះនៅក្នុងសវនាការនៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ខណៈដែលវិធានរបស់ អ.វ.ត.ក មិនមានចែងយ៉ាងដូច្នេះ

[៤៧] *សូមមើល* វិធានផ្ទៃក្នុងនៃនីតិវិធី និងភស្តុតាងរបស់ ICTY, វិធាន 92 *ស្ទួន*, វិធាននៃនីតិវិធី និងភស្តុតាងរបស់ SCSL, វិធាន 92*ស្ទួន*។

[៤៨] ក.ស.ព បានលើកឡើងនូវទឡ្ហីករណ៍ស្រដៀងគ្នាមួយ ទោះបីជាស្ថិតក្នុងស្ថានភាពខុសគ្នាក៏ដោយ។ ក.ស.ព អះអាងថាអ្នកធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក អាចបានដឹងអំពីលក្ខន្តិកៈរបស់ ICTY ហើយតាមរយៈការប្រើពាក្យពេចន៍ស្រដៀងគ្នានៅក្នុងមាត្រា២៩នោះ ពួកគេ អាចមានបំណងប្រើពាក្យពេចន៍នេះក្នុងអត្ថន័យដូចគ្នា។ *សូមមើល* សំណើរបស់ព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត , ថ្ងៃទី 17 ខែ មិថុនា ឆ្នាំ 2011, E100, កថាខណ្ឌ15។

[៤៩] វិធានផ្ទៃក្នុងនៃនីតិវិធី និងភស្តុតាងរបស់ ICC, វិធាន 68 (ក)។

[៥០] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 20។

ទេ។ នៅ អ.វ.ត.ក យើងមិនចាំបាច់ត្រូវមានការរឹតត្បិតច្បាស់លាស់ចំពោះការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សី នៅពេលដែលសាក្សីនោះមិនបង្ហាញខ្លួននៅក្នុងសវនាការឡើយ ពីព្រោះវិធាន ៨៤(១) ផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិដាច់ខាតដើម្បីតទល់ជាមួយសាក្សីនៅពេលសវនាការ។ ក.ស.ព មិនបានបង្ហាញឱ្យឃើញថា វិធានស្តីពីនីតិវិធីនៅតុលាការ ICTY និង SCSL គួរជាជម្រើសប្រសើរជាងវិធាននៅតុលាការ ICC ឡើយ។

១៩. បើទោះជាអង្គជំនុំជម្រះសាលាដំបូង ពិតជាយល់ឃើញថាមានចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក <u>ហើយ</u>ទំនងជានឹងអនុវត្តតាមនីតិវិធីរបស់តុលាការ ICTY និង SCSL ជាជាងតុលាការ ICC ក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែទទួលយកចម្លើយសាក្សី ដោយមិនកោះហៅសាក្សីឱ្យធ្វើសក្ខីកម្ម តែនៅពេលណាដែលលក្ខខណ្ឌជាក់លាក់មួយចំនួនត្រូវបានបំពេញតែប៉ុណ្ណោះ[៥១]។ ដូចដែល ក.ស.ព បានទទួលស្គាល់រួចហើយ កំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលទទួលយកដោយតុលាការ ICTY និង SCSL ជាទូទៅ គឺជាចម្លើយដែលពាក់ព័ន្ធទៅនឹងភស្តុតាងបទឧក្រិដ្ឋ[៥២] ហើយចំពោះចម្លើយដែលនឹងបញ្ជាក់បង្ហាញអំពីអំពើ ឬការប្រព្រឹត្តិរបស់ជនជាប់ចោទ ដែលអាចបង្ហាញថា ជនជាប់ចោទបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមមួយ ឬមានចេតនាចាំបាច់ ដូចគ្នាទៅនឹងចេតនារបស់បុគ្គលដែលបានប្រព្រឹត្តិឧក្រិដ្ឋកម្មនានា <u>ត្រូវតែត្រូវដកចេញ</u> បើសិនជាសាក្សីមិនធ្វើសក្ខីកម្មនៅក្នុងសវនាការទេនោះ[៥៣]។

២០. ក.ស.ព បានអះអាងថា លោកសហមេធាវីការពារក្តីអន្តរជាតិ Michael G. Karnavas "យល់

---

[៥១] អង្គជំនុំជម្រះសាលាដំបូង យល់ថានៅ ICTY និង SCSL " កត្តាដែលត្រូវពិចារណាថាតើត្រូវទទួលយកភស្តុតាងបែបនេះ ឬមិនទទួលយកនោះ រួមមានកាលៈទេសៈដែលចម្លើយនោះ ត្រូវបានធ្វើ និងត្រូវបានកត់ត្រា ថាតើចម្លើយបើកផ្លូវឲ្យមានការសួរដេញដោលដោយភាគីប្រឆាំងដែលកំពុងប្រើភស្តុតាងនេះ ដើម្បីចោទប្រកាន់ឬទេនិងថាតើចម្លើយនេះទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលនាំឲ្យមានភស្តុតាងផ្សេងទៀតដែរឬទេ។ នៅពេលដែលភស្តុតាងឈានទៅរកការបង្ហាញពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នោះ នេះគឺជាកត្តាដែលប្រឆាំងនឹងភាពអាចទទួលយកបានបែបនេះ ឬក៏ជាផ្នែកនៃភស្តុតាងនោះ។" *សំណុំរឿង កាំង ហ្គេកអ៊ាវ* 001/18-07-2007-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩, E43/4, កថាខណ្ឌ15។

[៥២] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ 22, 36។

[៥៣] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ17។

ព្រមប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍ ដែលមានចែងនៅក្នុងសេចក្ដីសន្និដ្ឋាននេះ"[៥៤]។ វាមានលក្ខណៈច្បាស់លាស់តាមរយៈប្រតិចារិត ដែល ក.ស.ព បានយោងទៅលើនោះថា សហមេធាវីការពារក្ដី លោក Karnavas នាពេលនោះកំពុងពិភាក្សាលើនីតិវិធីនៅតុលាការពិសេសនានា ហើយថាការពិភាក្សានេះ មិនបង្ហាញថាការអនុវត្តនៅឯតុលាការទាំងនោះអាចអនុវត្តបាននៅ អ.វ.ត.ក នោះឡើយ។ មុននឹងពិភាក្សាលើការអនុវត្តអន្តរជាតិ សហមេធាវី លោក Michael Karnavas បានលើកឡើងថា៖ "**សូមយើងចងចាំផងដែរថា នេះគឺជាតុលាការកម្ពុជា តុលាការនេះគឺនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ហើយយើងគួរតែងាកទៅមើលគំរូអន្តរជាតិ តែខណៈណា ជាអាទិ៍ គំរូក្នុងស្រុកកម្ពុជាមិនមានលក្ខណៈគ្រប់គ្រាន់តែប៉ុណ្ណោះ ឬខណៈណាមានចន្លោះប្រហោងតែប៉ុណ្ណោះ**"[៥៥]។ ក.ស.ព ប្រដូចដោយមិនត្រឹមត្រូវ ថាការអនុវត្តរបស់<u>មេធាវីការពារក្ដី</u>ចំពោះការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរនៅក្នុងសំណុំរឿង *រដ្ឋអាជ្ញាតទល់នឹង Prlić* នៅតុលាការ ICTY ថាជាការអនុវត្តដូចគ្នាទៅនឹងអ្វីដែលស្នើឡើងនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ ក.ស.ព នាពេលបច្ចុប្បន្ននេះ។ សិទ្ធិក្នុងការសាកសួរសាក្សី គឺជាសិទ្ធិជាសារវ័ន្តរបស់<u>ជនជាប់ចោទ</u> មិនមែនជាសិទ្ធិរបស់ព្រះរាជអាជ្ញាទេ។ សិទ្ធិរបស់រដ្ឋអាជ្ញានៅក្នុងនីតិវិធី ដើម្បីសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខនៅក្នុងសវនាការដែលដឹកនាំដោយភាគី (adversarial trials) មិនអាចប្រដូចទៅនឹងសិទ្ធិរបស់ជនជាប់ចោទនេះបានឡើយ[៥៦]។

## ៣. ការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី ដោយមិនកោះហៅសាក្សីទាំងនោះឱ្យធ្វើសក្ខីកម្មនៅក្នុងសវនាការ មិនប្រាកដថានឹងធានាឱ្យមានភាពងាយ

[៥៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ23។

[៥៥] ប្រតិចារឹក, ថ្ងៃទី 5 ខែ មេសា ឆ្នាំ 2011, E1/2.1, ទំព័រ 89។

[៥៦] "សិទ្ធិតាមនីតិវិធីរបស់រដ្ឋអាជ្ញាក្នុងការសួរសាក្សីរបស់ភាគីបដិបក្ខ ... តាមមធ្យោបាយណាក៏ដោយ មិនអាចប្រដូចសិទ្ធិ *ជាសារវ័ន្ត*ទៅនឹងសិទ្ធិសួរសាក្សីរបស់ភាគីបដិបក្ខរបស់ជនជាប់ចោទឡើយ ដោយហេតុថាជនជាប់ចោទ យល់ឃើញថាមូលដ្ឋានគ្រឹះមានចែងនៅក្នុងអត្ថបទរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាសម្រាប់ការការពារសិទ្ធិ និងសេរីភាពជាសារវ័ន្ត ។ STEFANO MAFFEI, សិទ្ធិរបស់ប្រជាជនអឺរ៉ុបក្នុងការតទល់មុខគ្នាក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ៖ សាក្សីដែលអវត្តមាន, អនាមិក និងងាយរងគ្រោះ *9 THE EUROPEAN RIGHT TO CONFRONTATION IN CRIMINAL PROCEEDINGS: ABSENT, ANONYMOUS AND VULNERABLE WITNESSES* 10-11 (ការបោះពុម្ពផ្សាយច្បាប់ Europa ឆ្នាំ ២០០៦)។

## ស្រួលដល់កិច្ចដំណើរការនីតិវិធីឡើយ

២១. ក.ស.ព អះអាងថា ការអនុវត្តនៃការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយមិនកោះហៅសាក្សីឱ្យចូលធ្វើសក្ខីកម្មនៅក្នុងសវនាការ នឹងអនុញ្ញាតឱ្យសវនាការប្រព្រឹត្តិទៅដោយមានភាពងាយស្រួលដោយសមហេតុផល[៥៧]។ ក.ស.ព អះអាងថា "ការអនុញ្ញាតឱ្យជនជាប់ចោទដែលជំនះចង់សួរដេញដោលសាក្សីច្រើនរយនាក់ ដែលកំណត់ហេតុរបស់ពួកគាត់មានរួចស្រេចហើយក្នុងសំណុំរឿង មិនថាកំណត់ហេតុទាំងនោះទាក់ទិននឹងអំពើរបស់ជនជាប់ចោទ ឬផ្នែកណាមួយនៃសំណុំរឿង ឬមិនថាកំណត់ហេតុទាំងនោះត្រូវបានបញ្ជាក់ដោយភស្តុតាង *ផ្ទាល់មាត់* និង/ឬ ជាលាយលក្ខណ៍អក្សរ និងមិនថាមានផលប៉ះពាល់ដល់រយៈពេលនៃសវនាការប៉ុន្មានទេ គឺវាដូចគ្នានឹងការអនុញ្ញាតឱ្យជនជាប់ចោទធ្វើឱ្យខូចដល់កិច្ចដំណើរការនីតិវិធី និងរំលោភបំពានដំណើរការរបស់តុលាការ"[៥៨]។ ការអះអាងបែបនេះមិនសមហេតុផលឡើយ។ ក.ស.ព មិនអាចអះអាងដោយមានភាពជឿជាក់ថា មេធាវីការពារក្តីនឹង "ធ្វើឱ្យខូចដល់កិច្ចដំណើរការនីតិវិធី" ដោយសារតែមេធាវីការពារក្តីមានសិទ្ធិសាកសួរសាក្សីឡើយ។ ប្រសិនបើ ក.ស.ព ព្រួយបារម្ភអំពីរយៈពេលនៃការជំនុំជម្រះក្តី ហើយមិនប្រាថ្នាឱ្យមានការសាកសួរដេញដោលសាក្សី "រាប់រយនាក់" នៅក្នុងការជំនុំជម្រះក្តីទេនោះ ក.ស.ព មិនគួរស្នើសុំដាក់កំណត់ហេតុចម្លើយសាក្សីរាប់រយ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។ ក.ស.ព មិនអាច ហើយមិនគួរបង្វែរការស្តីបន្ទោសមកលើមេធាវីការពារក្តី ដោយសារតែការខកខានរបស់ខ្លួនក្នុងការកំណត់ដោយសមហេតុផលនូវភស្តុតាងដែលខ្លួនស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ ដូចបានរៀបរាប់គ្រប់គ្រាន់រួចហើយ បើទោះជា លោក អៀង សារី មានសិទ្ធិដាច់ខាតដើម្បីសាកសួរដេញចោលសាក្សីដាក់បន្ទុកក៏ដោយ ក៏យើងមិនអាចបកស្រាយថា គាត់នឹងអនុវត្តសិទ្ធិនេះនៅក្នុងគ្រប់ឱកាសទាំងអស់ដែលមាននោះទេ លើកលែងតែពេលណាដែលចាំបាច់តែប៉ុណ្ណោះ។ ការពិចារណាទៅលើអ្វីដែលអាចកើតមានឡើងនាពេលអានាគត នឹងគ្រាន់តែជំរុញឱ្យមានកង្វល់ដែលមិនចាំបាច់តែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិគ្រប់គ្រាន់ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីកំហិតការសាកសួរដេញដោលសាក្សីណាមួយ នៅពេលដែលសំណួរទាក់ទងទៅនឹងបញ្ហាដែលមិនពាក់ព័ន្ធ

[៥៧] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព, កថាខណ្ឌ 26, 34។

[៥៨] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ34។

ឬច្រំដែលឥតប្រយោជន៍។

**ខ. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា លោក អៀង សារី មិនមានសិទ្ធិដាច់ខាតដើម្បីសាកសួរដេញដោលសាក្សីទេនោះ អង្គជំនុំជម្រះត្រូវពិចារណាដោយប្រុងប្រយ័ត្នអំពីភាពអាចទទួលយកបាន និងតម្លៃជាភស្តុតាងនៃកំណត់ហេតុចម្លើយសាក្សីនីមួយៗ**

២២. ក.ស.ព មិនទាន់បានដាក់បញ្ជីឯកសារសម្រាប់ប្រធានបទចំនួនបួនដំបូងសម្រាប់ការជំនុំជម្រះក្តីនៅឡើយទេ ហើយយើងមិនទាន់ដឹងយ៉ាងជាក់លាក់នៅឡើយទេថាតើកំណត់ហេតុស្តាប់ចម្លើយសាក្សីណាមួយ ដែល ក.ស.ព មានបំណងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកដោយមិនស្តាប់សក្ខីកម្មសាក្សីនោះ។ នៅពេលបញ្ជីឯកសារនោះត្រូវបានដាក់រួចហើយ មេធាវីការពារក្តីនឹងមានលទ្ធភាពច្រើនជាងនេះក្នុងការបង្ហាញការជំទាស់របស់ខ្លួនបដិសេធការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីជាក់លាក់ទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងដំណាក់កាលនេះ វាជាការសំខាន់ក្នុងការរំឭកឡើងវិញដែរថា ក.ស.ច.ស ដែលមានអាណត្តិក្នុងការបំពេញកិច្ចស៊ើបសួរតែម្នាក់ឯងគត់នោះ[៥៩] បានប្រមូល និងដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើន ដែលធ្វើឡើងដោយ ក.ស.ព និងបុគ្គល និងអង្គការនានានៅខាងក្រៅតុលាការ ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា (ហៅកាត់ថា "DC-Cam")។ លោក អៀង សារី មិនមានឱកាសណាមួយ ដើម្បីសាកសួរសាក្សីទាំងនេះ ឬសាក្សីណាមួយ[៦០] នៅពេលដែលពួកគាត់បានផ្តល់

[៥៩] អនុស្សរណៈរបស់ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី, ថ្ងៃទី 10 ខែ មករា ឆ្នាំ 2008, ទំព័រ2។

[៦០] ក្នុងអំឡុងពេលស៊ើបសួរ ក.ស.ច.ស បានពន្យល់ថាការតទល់មុខគ្នាក្នុងដំណាក់កាលស៊ើបសួរ ត្រូវបានរៀបចំធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់ក.ស.ច.ស ដើម្បីបញ្ជាក់ច្បាស់នូវសក្ខីកម្មដែលមានលក្ខណៈផ្ទុយគ្នា ហើយក.ស.ច.ស ក៏បានពន្យល់ថាការចូលរួមក្នុងការតទល់មុខគ្នា នឹងនាំឱ្យមានការលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ *សូមមើល* លិខិតរបស់ក.ស.ច.ស ផ្ញើជូនសហមេធាវីការពារក្តីនួន ជា៖ ការឆ្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពី ការស៊ើបអង្កេត ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ A110/I។ *សូមមើលផងដែរ* លិខិតរបស់ ក.ស.ច.ស ផ្ញើជូនសហមេធាវីការពារក្តី អៀង ធីរិទ្ធ៖ ចម្លើយតបនឹងពាក្យសុំ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ទាមទារឱ្យមានការការពារសិទ្ធិការពារខ្លួននៅពេលសួរចម្លើយ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៨, A178/I។ លិខិតរបស់ ក.ស.ច.ស ផ្ញើជូនសហមេធាវីការពារក្តី នួន ជា៖ ចម្លើយតប ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ចំពោះសំណើសុំការបំភ្លឺទាក់ទងនឹងការតទល់មុខគ្នា ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៨, D114/1។

ចម្លើយនោះឡើយ។ <u>មិនត្រូវ</u>បានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនោះឡើយ <u>លើកលែងតែ</u> សាក្សីទាំងនោះត្រូវបានសាកសួរដេញដោលនៅក្នុងសវនាការជាមុនសិន។

២៣. យើងដឹងតិចតួចណាស់អំពីកាលៈទេសៈ ដែលកំណត់ស្តាប់ចម្លើយសាក្សីទាំងនេះត្រូវបានធ្វើឡើង ឬអំពីបទពិសោធន៍ និងគុណវឌ្ឍន៍របស់អ្នកសម្ភាសន៍ទាំងនោះ។ ចេតនារបស់អ្នកសម្ភាសន៍ទាំងនោះអាចឱ្យគេចោទសួរបាន។ ជាឧទាហរណ៍ DC-Cam ត្រូវបានបង្កើតឡើងដោយសារតែមានច្បាប់របស់សហរដ្ឋអាមេរិកស្តីពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅឆ្នាំ ១៩៩៤[៦១]។ ច្បាប់ស្តីអំពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា នេះសន្មតថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថាមានអត្ថិភាពនៃអំពើប្រល័យពូជសាសន៍[៦២]។ អាណត្តិរបស់ DC-Cam គឺត្រូវ "ប្រមូលទន្និន័យពាក់ព័ន្ធនានាទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា"[៦៣]។ ការងារនេះនៅតែជាការងារមួយផ្នែកនៃបេសកកម្មរបស់មជ្ឈមណ្ឌលនេះដដែលនាពេលបច្ចុប្បន្ន[៦៤]។ មជ្ឈមណ្ឌលនេះមិនត្រូវបានបង្កើតឡើង ដើម្បីស្វែង

---

លោក អៀង សារី មិនបានជ្រើសរើសលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងមិនត្រូវបានស្នើឱ្យធ្វើដូច្នោះ ហើយមិនបានចូលរួមក្នុងការតទល់មុខគ្នាក្នុងអំឡុងពេលស៊ើបសួរឡើយ។

[៦១] 22 U.S.C. 2656, ផ្នែកឃ, §§ 571–74។

[៦២] *ដូចជើងទំព័រខាងលើ*, § 572. "ក. ជាទូទៅ ស្របតាមច្បាប់អន្តរជាតិ វាជាគោលនយោបាយរបស់សហរដ្ឋអាមេរិកក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងដើម្បីនាំខ្លួនសមាជិកខ្មែរក្រហមយកមកជំនុំជម្រះក្តី សម្រាប់ឧក្រិដ្ឋកម្មរបស់ពួកគេប្រឆាំងនឹងមនុស្សជាតិក្នុងប្រទេសកម្ពុជា ដែលបានប្រព្រឹត្តចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩។ ខ.ការជំរុញឱ្យមានសកម្មភាពជាក់លាក់នានា៖ ចុងក្រោយ សភាសហរដ្ឋអាមេរិកជំរុញឱ្យប្រធានាធិបតី ១. ប្រមូលផ្តុំ ឬផ្តល់ជំនួយដល់អង្គការ និងបុគ្គលដែលមានលក្ខណៈសមស្រប ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា, ២. ក្នុងស្ថានភាពដែលប្រធានាធិបតី យល់ឃើញថាមានភាពសមស្រប ប្រធានាធិបតីលើកទឹកចិត្តឱ្យបង្កើតតុលាការព្រហ្មទណ្ឌជាតិ ឬអន្តរជាតិសម្រាប់ជំនុំជម្រះក្តីជនទាំងឡាយណា ដែលត្រូវបានចោទពីបទប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា និង ៣. ប្រសិនបើមានការចាំបាច់ ត្រូវផ្តល់ឱ្យតុលាការជាតិ និងអន្តរជាតិនោះនូវព័ត៌មានដែលប្រមូលបាន ដោយអនុលោមតាមកថាខណ្ឌ (១)។

[៦៣] *ដូចជើងទំព័រខាងលើ។*

[៦៤] គេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្លែងថា៖ "មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងធ្វើការងារដើម្បីចងក្រងឡើងវិញនូវប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសកម្ពុជា ដែលភាគច្រើនមិនមានភាពច្បាស់លាស់ដោយសារអណ្តាតភ្លើងសង្គ្រាម និងអំពើប្រល័យពូជសាសន៍" http://www.dccam.org/Abouts/History/Histories.htm។

រកការពិត ឬដើម្បីសម្រេចថាតើអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពិតជាបានកើតមានឡើងមែន ឬមិនមែននោះទេ។ ផ្ទុយទៅវិញ មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងដើម្បីបញ្ជាក់បន្ថែមអំពីសេចក្ដីសន្និដ្ឋានទុកជាមុនថាមានអំពើទាំងនេះ។ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយ DC-Cam មិនអាចចាត់ទុកថាអាចជឿជាក់បានគ្រប់គ្រាន់ ដើម្បីទទួលយកមកធ្វើជាភស្តុតាងបានទេ លុះត្រាតែសាក្សីដែលផ្ដល់បទសម្ភាសន៍ទាំងនោះបង្ហាញខ្លួននៅក្នុងសវនាការសម្រាប់ការសាកសួរដេញដោល។

២៤. អង្គជំនុំជម្រះសាលាដំបូងធ្លាប់ដកចេញកំណត់ហេតុស្ដាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយ DC-Cam ដោយសារតែសាក្សីទាំងនោះបានទទួលមរណភាព ដែលអង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់គាត់ មិនសមស្របក្នុងការបញ្ជាក់បង្ហាញអំពីអង្គហេតុ ដែលបានអះអាងនៅក្នុងកំណត់ហេតុទាំងនោះបានឡើយ[៦៥]។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សាក្សី ឬអ្នកបកប្រែភាសានៃកំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់ DC-Cam ដែលត្រូវបានដកចេញនោះ មិនបានធ្វើការស្បថនោះទេ[៦៦]។ ពិតណាស់ សូម្បីតែនៅតុលាការ ICTY ដែលអនុញ្ញាតយ៉ាងច្បាស់លាស់ ក្នុងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅក្នុងស្ថានភាពជាក់លាក់មួយចំនួន នៅពេលដែលសាក្សីទាំងនោះមិនបានធ្វើសក្ខីកម្មនៅក្នុងពេលសវនាការក៏ដោយ ក៏តុលាការនោះនៅតែទាមទារឱ្យមានលក្ខខណ្ឌតម្រូវមួយដែលថា កំណត់ហេតុស្ដាប់ចម្លើយសាក្សី ត្រូវមានភ្ជាប់មកជាមួយនូវសេចក្ដីប្រកាសសាក្សីមួយរបស់បុគ្គល ដែលធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ថាខ្លឹមសារនៃកំណត់ហេតុនោះពិតប្រាកដ និងត្រឹមត្រូវទៅតាមចំណេះដឹង និងការជឿជាក់របស់បុគ្គលនោះ[៦៧]។ ក.ស.ព អះអាងថា លក្ខខណ្ឌតម្រូវមួយនេះនឹងមិនសមស្របអនុវត្តនៅ អ.វ.ត.ក ទេ "នៅក្នុងករណីនៃកំណត់ហេតុសម្ភាសន៍ជាលាយលក្ខណ៍អក្សរ ដែលបានបង្កើតឡើងក្នុងអំឡុងកិច្ចស៊ើបសួរ"[៦៨]។ ក.ស.ព មិនបានពន្យល់ថាហេតុអ្វី

---

[៦៥] *សំណុំរឿង កាំង ហ្គេកអ៊ាវ* 001/18-07-2007-អ.វ.ត.ក/អ.ជ.ស.ជ, សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ E43/4, កថាខណ្ឌ, កថាខណ្ឌ16។

[៦៦] *ដូចជើងទំព័រខាងលើ។*

[៦៧] វិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី វិធាន៩២ស្ទួន (ខ)។

[៦៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ក.ស.ព កថាខណ្ឌ 25។

បានជាខ្លួនពិចារណាឃើញថា លក្ខខណ្ឌតម្រូវមួយនេះមិនមានភាពសមស្រប។ ក.ស.ព អះអាងបន្តថា អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាថាតើលិខិតបញ្ជាក់អំពីកំណត់ហេតុដែលប្រមូលបានមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធី អ.វ.ត.ក មានភាពសមស្របដែរឬទេ ឬថាតើចម្លើយនានាអាចត្រូវបានទទួលយកដែរឬទេ ប្រសិនបើសាក្សីបានទទួលមរណភាព ឬមិនអាចឱ្យគេរកឃើញ[៦៩]។ អង្គជំនុំជម្រះសាលាដំបូងគួរតែអនុវត្តតាមនីតិវិធីរបស់ខ្លួនដែលមានកន្លងមកពាក់ព័ន្ធទៅនឹងបញ្ហានេះ ហើយបដិសេធមិនទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់សាក្សីណាដែលបានទទួលមរណភាពហើយនោះ និងរបស់សាក្សីណាដែលមិនបានធ្វើការស្បថ[៧០]។ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១[៧១] មិនមានលក្ខណៈដាច់ខាតឡើយ ដោយហេតុថាមេធាវីការពារក្តីនៅក្នុងសំណុំរឿងនោះ មិនជំទាស់ទៅនឹងបញ្ហាអង្គច្បាប់ជាច្រើន ដោយរួមទាំងបញ្ហានីតិវិធីនានាផងដែរ ដែលតាមការសន្មត ពីព្រោះថាបញ្ហាដែលសំខាន់តែមួយគត់ គឺការកំណត់ទោសរបស់ ឌុច ដែលគាត់នឹងទទួលចំពោះអំពើឧក្រិដ្ឋរបស់គាត់ដែលគាត់បានទទួលស្គាល់។ តាមរយៈការរៀបរាប់មកនេះ លោក អៀង សារី មិនគួរទទួលរងបញ្ហា ដោយសារតែការខ្វះការយកចិត្តទុកដាក់ ឬយុត្តិសាស្ត្រការពារក្តីរបស់មេធាវីរបស់ ឌុច ឡើយ។

២៥. កំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយ ក.ស.ព មិនគួរត្រូវបានទទួលយកទេ ប្រសិនបើសាក្សីទាំងនោះមិនត្រូវបានសាកសួរដេញដោលនៅក្នុងសវនាការជាមុនសិន។ ក.ស.ព មានការចាប់អារម្មណ៍យ៉ាងច្បាស់នៅក្នុងការផ្តោតទៅលើភស្តុតាងដាក់បន្ទុក។ សំណួរដែលមានលក្ខណៈដោះបន្ទុក នឹងមិនទំនងជាត្រូវបានសួរដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ព ឡើយ។ នៅក្នុងប្រទេសអាល្លឺម៉ង់ ក្រមព្រហ្មទណ្ឌនៃប្រទេសនេះ ហាមឃាត់យ៉ាងជាក់ច្បាស់ចំពោះបុគ្គលទីបីដែលមិនចូលរួមនៅក្នុងដំណើរការសម្រេចសេចក្តីចុងក្រោយ ឱ្យប្រមូលភស្តុតាងដែលនឹងត្រូវប្រើ

---

[៦៩] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ 39។

[៧០] *សំណុំរឿង កាំង ហ្គេកអ៊ាវ* 001/18-07-2007-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ E43/4, កថាខណ្ឌ, កថាខណ្ឌ16។

[៧១] វាត្រូវបានក.ស.ព យោងក្នុងកថាខណ្ឌ ៣០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ក.ស.ព។ ជើងទំព័ររបស់ក.ស.ព មិនត្រឹមត្រូវឡើយ។ ហេតុដូច្នេះហើយ សហមេធាវីការពារក្តី មិនអាចពិនិត្យមើលសិទ្ធិអំណាច ដែលក.ស.ព ផ្អែកលើឡើយ។

ប្រាស់នៅក្នុងតុលាការនោះ[៧២]។ អង្គជំនុំជម្រះសាលាដំបូងគួរតែអនុវត្តតាមវិធីសាស្ត្របែបនេះ ហើយទទួលយកតែកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងឡាយណា ដែលប្រមូលបានដោយសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុនានា ដោយមិនកោះហៅសាក្សីដែលផ្តល់ចម្លើយនោះមកឱ្យធ្វើសក្ខីកម្មនៅក្នុងសវនាការ នោះទេ។

២៦. ចម្លើយសាក្សីដែលប្រមូលបានដោយអ្នកស៊ើបអង្កេត ឬអ្នកវិភាគនានារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ដែលខុសពីសហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់) មិនអាចឱ្យមានការជឿជាក់គ្រប់គ្រាន់ ដើម្បីទទួលយកធ្វើជាភស្តុតាងបានទេ ប្រសិនបើមិនផ្តល់សិទ្ធិឱ្យជនជាប់ចោទដើម្បីធ្វើការតទល់សាក្សីទេនោះ។ សមាជិកបុគ្គលិករបស់ ក.ស.ច.ស មួយចំនួន ដោយរួមទាំងអ្នកទាំងឡាយណាដែលដឹកនាំកិច្ចសម្ភាសន៍សាក្សីផងដែរនោះ មានទំនាក់ទំនងពីមុនៗជាមួយនឹង ក.ស.ព ឬ មជ្ឈមណ្ឌល DC-Cam ដែលអាចប៉ះពាល់ដល់ភាពគួរឱ្យជឿជាក់បាននៃចម្លើយសាក្សីទាំងនោះ[៧៣]។ វាជាការសំខាន់ក្នុងការគូសបញ្ជាក់អំពីការណែនាំរបស់លោកចៅក្រម Lemonde ទៅកាន់អ្នកស៊ើបអង្កេតជាន់ខ្ពស់របស់គាត់ថា គាត់ "ចង់ឱ្យយើងរកបានភស្តុតាងដាក់បន្ទុកច្រើន

---

[៧២] "The *Unmittelbarkeitsprinzip* [គោលការណ៍នៃការបង្ហាញភស្តុតាងនៅចំពោះមុខចៅក្រមពេញសិទ្ធិ] ហាមឃាត់មិនឲ្យតុលាការប្រគល់សិទ្ធិឲ្យបុគ្គលទី៣ ទទួលយកភស្តុតាងដែលមិនពាក់ព័ន្ធនឹងដំណើរការសម្រេចចិត្តចុងក្រោយឡើយ។ ដូច្នេះ ក្នុងពេលធ្វើការជំនុំជម្រះក្តីជាប្រក្រតី តុលាការមួយ មិនអាចណែនាំឲ្យមន្ត្រីមួយរូបទៀតទៅជួបសាក្សីណាមួយដូចជាសាក្សីរស់នៅបរទេស ឬស្នាក់នៅក្នុងមន្ទីរពេទ្យក្នុងទីក្រុងមួយទៀត ហើយស្តាប់ចម្លើយសាក្សីរូបនោះឡើយ។ ហើយតុលាការ ក៏មិនអាចប្រើប្រាស់កំណត់ត្រារបស់មន្ត្រីនោះជាភស្តុតាងឡើយ ក្នុងករណីមិនបានលក្ខខ័ណ្ឌដែលគេហៅថា *kommissarische Beweisaufnahme* (ការទទួលយកភស្តុតាងតាមរយៈការប្រទានសិទ្ធិ *commissary taking of evidence*) ក្រោម §§ 223 – 225 ។" Michael Bohlander, *ទស្សនៈទានជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ – សេចក្តីផ្តើម*, 1 DURHAM L. REV. 1, 21 (2011)។

[៧៣] *សូមមើល, ឧទាហរណ៍,* សំណើសុំព័ត៌មានទាក់ទងនឹងអត្ថិភាពដ៏សំខាន់នៃទំនាស់ផលប្រយោជន៍របស់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត Stephen Heder ចុះថ្ងៃទី 30 ខែ មករា ឆ្នាំ 2009, A252។ សាលដីកាលើពាក្យបណ្តឹងរបស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស លើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីអ្នកស្រី អៀង ធីរិទ្ធ សុំឱ្យស៊ើបអង្កេតទៅលើតួនាទីរបស់លោកអ៊ីសា ឧស្មាន់ នៅក្នុងការស៊ើបសួរ សុំឱ្យដកចេញកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន និងសុំឱ្យស្តាប់ចម្លើយសាក្សីមួយចំនួនជា ថ្មីម្តង ទៀត ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១០ ,D361/2/4។

ជាងភស្តុតាងដោះបន្ទុក"[៧៤]។ លោកចៅក្រម Lemonde មិនដែលបដិសេធឲ្យច្បាស់ថាមិនបាន ផ្តល់ការណែនាំបែបនេះឡើយ បើទោះជាគាត់បានអះអាងថាការនិយាយបែបនេះគឺគ្រាន់តែជាការ លេងសើចក៏ដោយ[៧៥]។ បន្ថែមលើនេះ នៅក្នុងកិច្ចសម្ភាសន៍សាក្សីមួយចំនួន អ្នកស៊ើបអង្កេតរបស់ ក.ស.ចៅ.ស ទំនងជាបានសួរសំណួរ ដោយមានចម្លើយគិតទុកក្នុងចិត្តរួចទៅហើយ និង/ឬ មិន បានសួរសំណួរពាក់ព័ន្ធដើម្បីបញ្ជាក់ឡើយ[៧៦]។ ក្នុងករណីនេះ ផលប្រយោជន៍របស់មេធាវីការពារ ក្តីមិនត្រូវបានការពារឡើយ។

២៧. ចម្លើយសាក្សីដែលអ្នកស៊ើបអង្កេត ក.ស.ចៅ.ស បានប្រមូលមក មិនអាចជំនួសឱ្យការសាកសួរ ដេញដោលសាក្សីទាំងនេះនៅក្នុងសវនាការបានឡើយ។ ដូចដែលបានពន្យល់ដោយវិទូដ៏ល្បីល្បាញ ខាងជំនាញច្បាប់ លោក William Blackstone៖

> ការសាកសួរដេញដោលសាក្សីដោយបើកចំហ *ដោយផ្ទាល់មាត់* នៅចំពោះមុខមនុស្សជាតិ អាចនាំទៅដល់ ការបង្ហាញការពិត ប្រសើរជាងការសាកសួរជាអសាធារណៈ និងដោយសម្ងាត់ ដោយមានកត់ត្រាជាលាយ លក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីមួយរូប ឬជំនួយការរបស់គាត់ នៅក្នុងតុលាការគ្រីស្តសាសនា និងនៅ តុលាការដទៃៗទៀតដែលអនុវត្តការងាររបស់ខ្លួនតាមប្រព័ន្ធច្បាប់ស៊ីវិល[៧៧] ដែលជារឿយៗ សាក្សីផ្តល់ សក្ខីកម្មជាអសាធារណៈដោយគាត់មានការខ្មាស់អៀន ក្នុងការធ្វើសក្ខីកម្មនៅក្នុងតុលាការផ្លូវការជា សាធារណៈ។ នៅក្នុងការផ្តល់សក្ខីកម្មជាអសាធារណៈបែបនេះ អ្នកកត់ត្រាដ៏ជំនាញ ឬដោយមិនប្រុង

---

[៧៤] *សូមមើល* សំណើរបស់លោក អៀង សារី សុំថ្កោលទោសចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឲ្យមាន សវនាការជាសាធារណៈ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩, ឯកសារលេខ 1, បើក ឧបសម្ព័ន្ធ១។

[៧៥] ចម្លើយតបរួមរបស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងបណ្តឹងជំទាស់ដែលត្រូវបានធ្វើក្នុងនាម អៀង សារី និង ខៀវ សំផន ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៨។

[៧៦] *សូមមើល ឧទាហរណ៍* ឯកសារ D200/5, ទំព័រ៤, ដែលអ្នកបកប្រែត្រូវបានសួរថា "តើឯកសារទាំងនេះនិយាយអំពីការបោស សម្អាតឬ?" នៅពេលដែលមិនមានការលើកឡើងពេលមុនអំពីការបោសសម្អាតណាមួយឡើយ។ ឯកសារ D125/160 ដែលសាក្សីម្នាក់លើកឡើងថាលោកស្រី អៀង ធីរិទ្ធ មិនបានអនុញ្ញាតឲ្យគាត់ទៅធ្វើបុណ្យក្នុងភូមិកំណើតរបស់គាត់ ពីព្រោះលោកស្រី អៀង ធីរិទ្ធ ខ្លាចថាវាអាចមានប៉ះពាល់លើខ្លួនគាត់។ អ្នកស្តាប់ចម្លើយ មិនបានសួរលោកស្រីអៀង ធីរិទ្ធ ថាតើគាត់ខ្លាចអ្វីឡើយ ឬហេតុអ្វីបានជាគាត់ខ្លាចថាអាចប៉ះពាល់លើខ្លួនគាត់ឡើយ។

[៧៧] សូមកត់សម្គាល់ថាការលើកឡើងរបស់ Blackstone អំពីប្រព័ន្ធច្បាប់ civil law ចុះកាលបរិច្ឆេទក្នុងឆ្នាំ 1768។ មាន ការផ្លាស់ប្តូរច្រើនចាប់តាំងពីពេលនោះមក ដូចបានកត់សម្គាល់ខាងលើ ជាប្រពៃណី ប្រព័ន្ធច្បាប់បច្ចុប្បន្ននេះ និងជាពិសេស ក្នុងប្រទេសកម្ពុជា គោរពសិទ្ធិជនជាប់ចោទក្នុងការសាកសួរសាក្សីដាក់បន្ទុកលើជនជាប់ចោទ។

ប្រយ័ត្ន អាចធ្វើឱ្យសាក្សីម្នាក់និយាយពីអ្វីដែលគាត់មិនចង់ថា ដោយសារអ្នកកត់ត្រានោះបានរៀបចំសម្រួលសក្ខីកម្មរបស់សាក្សីដោយប្រើប្រាស់ទម្រង់ប្រយោគ និងភាសារបស់គាត់ផ្ទាល់។ ប៉ុន្តែនៅក្នុងតុលាការ សាក្សីមានសេរីភាពក្នុងការកែតម្រូវ និងពន្យល់ពីអត្ថន័យនៃសក្ខីកម្មរបស់គាត់ ប្រសិនមានការយល់ខុស ដែលសេរីភាពក្នុងការធ្វើបែបនេះមិនមានសម្រាប់គាត់ទេនៅពេល ដែលសក្ខីកម្មរបស់គាត់ត្រូវបានកត់ត្រាទុករួចហើយនោះ[៧៨]។

## IV. សេចក្តីសន្និដ្ឋាន និងសំណើ

២៨. វិធានផ្ទៃក្នុងមានលក្ខណៈច្បាស់លាស់ និងមិនមានភាពស្រពិចស្រពិលអ្វីឡើយ។ វិធានផ្ទៃក្នុងផ្តល់ឱ្យ លោក អៀង សារី នូវសិទ្ធិក្នុងការសាកសួរដេញដោលរាល់សាក្សីទាំងអស់ ដែលដាក់បន្ទុកមកលើរូបគាត់។ ការធានារបស់រដ្ឋធម្មនុញ្ញកម្ពុជាក្នុងការប្រកាន់ភ្ជាប់នូវកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏ធានាសិទ្ធិមួយនេះឱ្យ លោក អៀង សារី ផងដែរ។ មិនមានហេតុផលណាមួយ ដែលត្រូវរឹតត្បិតសិទ្ធិរបស់ លោក អៀង សារី នៅក្នុងការតទល់សាក្សី ដោយងាកទៅរកវិធានស្តីពីនីតិវិធីរបស់តុលាការ និងសាលាក្តីដទៃទៀត ដូចជាតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប តុលាការ ICTY ឬ SCSL នោះទេ។ បន្ថែមលើនេះ វាមិនត្រឹមត្រូវទេ ដែលយើងត្រូវអនុម័តយកបែបបទគំរូ ដែលតាមការសន្មតដើម្បីធានាឱ្យមានភាពងាយស្រួលនៃកិច្ចដំណើរការនីតិវិធី ដែលប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវបានធានា។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទំនោរនឹងទទួលយកចម្លើយសាក្សី ដោយមិនផ្តល់ឱ្យ លោក អៀង សារី នូវសិទ្ធិតទល់នឹងសាក្សីទាំងនោះទេ អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាដោយប្រុងប្រយ័ត្នទៅលើខ្លឹមសារ និងប្រភពនៃចម្លើយសាក្សីទាំងនោះ។ ចម្លើយសាក្សីជាច្រើននៅក្នុងសំណុំរឿង មិនអាចឱ្យជឿជាក់បានគ្រប់គ្រាន់ ដើម្បីទទួលយកមកធ្វើជាភស្តុតាងបានទេ កុំថាឡើយដល់ទៅផ្តល់តម្លៃជាភស្តុតាងឱ្យទៅចម្លើយសាក្សីទាំងនោះ ដោយមិនធ្វើការវាយតម្លៃទៅលើភាពត្រឹមត្រូវ ពិតប្រាកដ និងភាពដែលគួរឱ្យជឿជាក់បាននៃចម្លើយសាក្សី

[៧៨] WILLIAM BLACKSTONE, សេចក្តីអធិប្បាយអំពីច្បាប់របស់អង់គ្លេស *COMMENTARIES ON THE LAWS OF ENGLAND* 373-74 (ក្បាលទី 3, 1768)។

ទាំងនោះទេ។ ការបញ្ជាក់ពីភាពត្រឹមត្រូវ ពិតប្រាកដ និងភាពដែលគួរឱ្យជឿជាក់បាននៃចម្លើយសាក្សី អាចធ្វើទៅបានតាមរយៈការស្តាប់សក្ខីកម្ម និងតទល់ដេញដោល *ដោយផ្ទាល់មាត់*។

សម្រាប់សំអាងហេតុនានាដែលបានរៀបរាប់នៅក្នុងចម្លើយតបនេះ មេធាវីការពារក្តីសូមស្នើដោយគោរពថាអង្គជំនុំជម្រះ៖

ក. **គោរព**សិទ្ធិដាច់ខាតរបស់ លោក អៀង សារី ក្នុងការសាកសួរដេញដោលសាក្សីដាក់បន្ទុកមកលើគាត់។

ខ. **បដិសេធចោល**ការទទួលយកចម្លើយសាក្សីនានា ប្រសិនបើ លោក អៀង សារី មិនត្រូវបានផ្តល់ឱ្យនូវសិទ្ធិក្នុងការសាកសួរសាក្សីទេនោះ។

ជាជម្រើសផ្សេងពីនេះ ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលចម្លើយសាក្សីនានា ដោយមិនផ្តល់ឱ្យលោក អៀង សារី នូវសិទ្ធិសាកសួរដេញដោលសាក្សីទេនោះ សូមអង្គជំនុំជម្រះសាលាដំបូង៖

ក. **ពិចារណាដោយប្រុងប្រយ័ត្ន** អំពីភាពត្រឹមត្រូវ ពិតប្រាកដ និងភាពគួរឱ្យជឿជាក់បាននៃចម្លើយសាក្សីនីមួយៗ និងទទួលយកតែចម្លើយសាក្សីទាំងឡាយណា ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាមានភាពគួរឱ្យជឿជាក់បានក្នុងកម្រិតខ្ពស់តែប៉ុណ្ណោះ។

**ដោយក្តីគោរព**

| ________________________ | ________________________ |
| --- | --- |
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីការពារក្តីរបស់ លោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១១